ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ១៣៥/១៨ ជ.ក

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែកក្កដា និងទិសដៅខែសីហា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែកក្កដា ឆ្នាំ២០១៨នេះ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេស លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី រហូតដល់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវវិធានការក្នុង "ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឲ្យបាន" ដែលជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋយើងត្រូវបានគេនាំចេញទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ រហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ និងមិនមានឯកសារច្បាប់លាស់ ដែលជាបញ្ហាធ្វើឲ្យរាជរដ្ឋាភិបាលមានក្តីកង្វល់ដល់ពលករទាំងនោះកំពុងរងគ្រោះដោយការរត់ពន្ធមនុស្សឆ្លងដែនខុសច្បាប់។

ក្រោយពីរាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ ធ្វើការខុសច្បាប់ក្នុងប្រទេសថៃចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះប្រជាពលរដ្ឋធ្វើទេសន្តរប្រវេសន៍នៅក្រៅប្រទេស ដោយមានក្រុមប្រឹក្សាផ្តល់ភាពស្របច្បាប់កម្ពុជា បានសហការជាមួយរដ្ឋាភិបាលថៃ និងបានរៀបចំក្រុមការងារចុះចែកប័ណ្ណផ្តល់ភាពស្របច្បាប់ដល់ពលករខ្មែរដែលកំពុងធ្វើការនៅក្នុងប្រទេសថៃចំនួនជាងមួយលាននាក់ បានចប់ជាស្ថាពរប្រកបដោយជោគជ័យ ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០១៨នេះ មានដូចខាងក្រោមៈ

## ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំៈ

ក.១.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
    - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
    - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.១.២-សន្ធិសញ្ញាកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
    - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
    - ស្តីពី"បត្យាប័ន"
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
    - ស្តីពី "បញ្ជូនទណ្ឌិត"
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.១.៣-អនុស្សរណៈកំពុងរៀបចំ៖

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.១.៤-បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ"។
- ក្រសួងអប់រំ យុវជន និងកីឡា៖ ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបេបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយនាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

រដ្ឋបាលខេត្តចំនួន៣ ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន៥.៨២០ក្បាល (បាត់ដំបងចំនួន២.៨៣០ក្បាល បន្ទាយមានជ័យចំនួន២.៦៧៧ក្បាល និងខេត្តប៉ៃលិនចំនួន៣១៣ក្បាល) ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែកក្កដា ឆ្នាំ២០១៨នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន២.៦១៩លើក មានអ្នកចូលរួមសរុបចំនួន ៣៣១.១០៨នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួន៤៣៩.៥៩៩នាក់) ថយចុះចំនួន១០៨.៤៩១នាក់ ស្មើនឹង ៤៤.៦៧% ក្នុងនោះស្ត្រីមានចំនួន១៨០.១៣៧នាក់។ (ឧបសម្ព័ន្ធទី១)

### ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមផ្តល់បទសម្ភាសន៍៖
  - នៅស្ថានីយ៍ទូរស្សន៍បាយ័ន្ត BTV និងនៅស្ថានីយ៍ទូរទស្សន៍ NICE TV ក្រសួងមហាផ្ទៃ ស្តីពីការស៊ីឈ្នួលពរពោះជំនួស ឬការជួញដូរទារកឆ្លងដែន។
  - ជាមួយ Mr. Rodrigo(UN-WOMEN) និងលោក លឹម ទិត្យ (UN-ACT) អំពីករណីពពោះជំនួស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- លេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន៤៣លើក (ខេត្តកោះកុង៣១លើក និងខេត្តសៀមរាប១២លើក)។
- ខេត្តបាត់ដំបង អង្គការ **Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក១២២នាក់ ស្រី៥៤នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

### ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៤.១-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៥២៥គោលដៅ មានមនុស្សចំនួន២.៦១៦នាក់ (ស្រី១.៩៥៨នាក់) កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្តៈ (តាកែវ កែប កណ្តាល សៀមរាប មណ្ឌលគិរី ស្ទឹងត្រែង ព្រះសីហនុ កោះកុង ពោធិ៍សាត់ និងខេត្តរតនគិរី)។

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៦គោលដៅ សរុបចំនួន៧៥គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទចំនួន៣៥លើក ខេត្តអនុវត្តមានៈ ស្វាយរៀង ព្រះវិហារ កំពង់ស្ពឺ ស្ទឹងត្រែង និងព្រៃវែង។

**ខ.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

ខ.៥.១-វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន៤០៥.៨៥៣នាក់ (ស្រី១៥៦.៨១២នាក់) អនីតិជន៨.៤៤៥នាក់ (ស្រី២.៧៤១នាក់) ក្នុងនោះស្របច្បាប់ចំនួន១៩៧.២១០នាក់ (ស្រី៩០.៧០៩នាក់) អនីតិជន៦៥២នាក់ (ស្រី២៧៦នាក់) មិនស្របច្បាប់ចំនួន២០៨.៦៤៣នាក់ (ស្រី៦៦.១០៣នាក់) អនីតិជន៧.៧៩៣នាក់ (ស្រី២.៤៧៥នាក់) បើប្រៀបធៀបនឹងខែមុនមានការកើនឡើងចំនួន៦៣.៥៥១នាក់ ស្មើនឹង១៨.៥៦%។

ខ.៥.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញចំនួន១០៨លើក មនុស្សចំនួន២.១៥៥នាក់ (ស្រី៧៥០នាក់ កុមារ១៦៣នាក់)។ ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន៣៥លើក មនុស្ស៦៦នាក់ ស្រី៣៩នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន៨៣លើក មនុស្ស២.០៨៩នាក់ (ស្រី៧១១នាក់ កុមារ១៦៣នាក់)។

*របាយការណ៍ស្ថានភាព ៖*

- ក្រុមការងារអនុវត្តច្បាប់បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន៥២នាក់ (ស្រី១៤នាក់) ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព "និរទេស" តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុប៨៥ជើង/រថយន្ត មានមនុស្សចំនួន២.៩១៦នាក់ (ស្រី១.០៥៨នាក់) ក្នុងនោះកុមារ២៨២នាក់ (កុមារី១០១នាក់)។ បើប្រៀបធៀបនឹងខែមិថុនា ឆ្នាំ២០១៨ គឺមានការកើនឡើងចំនួន១.០២៣នាក់។
- **ខេត្តបាត់ដំបង**
  - បានទទួលពលករខ្មែរដែលអាជ្ញាធរថៃចាប់បញ្ជូនមកកម្ពុជាវិញសរុបចំនួន១២លើក មនុស្សចំនួន១១៣នាក់ ស្រី៤៣នាក់ កុមារី០៣នាក់។
  - បានទទួលសពពលករខ្មែរចំនួន០២នាក់តាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង។
- **ដោយឡែក** យោងរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

  ១-ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន៥៣លើក មនុស្សចំនួន៨៤នាក់ ស្រី១១នាក់ មាន២១សញ្ជាតិ។ អង្គភាពអនុវត្តៈ

  - អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន២៣លើក មនុស្ស៤១នាក់ ស្រី០៥នាក់ មាន១៤សញ្ជាតិ។

- បដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន៣០លើក មនុស្សចំនួន៤៣នាក់ សរុបមាន២០សញ្ជាតិ។

២-បទល្មើសស្នាក់នៅខុសច្បាប់ ៖

- ករណីហួសទិដ្ឋាការ មនុស្សចំនួន០២នាក់ ជាសញ្ជាតិអង់គ្លេស។
- ករណីលួចឆ្លងដែនខុសច្បាប់ មនុស្សចំនួន០៤នាក់ ស្រី០១នាក់ ជាសញ្ជាតិវៀតណាម។
- គ្មានឯកសារស្នាក់នៅ មនុស្សចំនួន០៥នាក់ សរុបមាន០៣សញ្ជាតិ(ឥណ្ឌា០១នាក់ ចិន ០២នាក់ និងនីហ្សេរីយ៉ា០២នាក់)។

៣-ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ៖

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ សរុបចំនួន១៤៩គ្រួសារ មនុស្សចំនួន៥៥០នាក់ ស្រី២៥៧នាក់ សញ្ជាតិវៀតណាម។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន១៣២គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់ ទៅនារីខ្មែរចំនួន១៥នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេស ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន៥គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង កំពង់ឆ្នាំង ព្រៃវែង និងត្បូងឃ្មុំ។

**គ.១-ការងារអនុវត្តច្បាប់**

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១០/០៩ករណី (បើប្រៀបធៀបនឹងខែមុនកើនឡើង០១ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន១១នាក់ (ស្រី០៣នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន១៦នាក់ មានអាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០១នាក់ និងអាយុ១៨ឆ្នាំឡើង០៧នាក់ (ប្រគល់មន្ទីរសង្គមកិច្ច០៨នាក់ និងគ្រួសារ០៨នាក់)។

១.អំពើជួញដូរមនុស្ស៖

បង្ក្រាបបាន០២/០៤ករណី (ថយចុះ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ (ស្រី០២នាក់)

និងសង្គ្រោះជនរងគ្រោះចំនួន០២នាក់ មានអាយុ១៨ឆ្នាំឡើងចំនួន០២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០១នាក់ និងគ្រួសារ០១នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ០២ |

២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖

បង្ក្រាបបាន០៨/០៥ករណី (កើនឡើង០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៩នាក់ (ស្រី០១នាក់) និងសង្គ្រោះជនរងគ្រោះចំនួន១៤នាក់ មានអាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០១នាក់ និងអាយុ១៨ឆ្នាំឡើង០៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៧នាក់ និងឲ្យគ្រួសារ០៧នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ស្ថានទម្រង់ទោសនៃសញ្ញាវកម្ម | ០១ | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ |
| *សរុប* | *០៨ នាក់* | *០៩ នាក់* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

**ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ**

- យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែររងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការ IOM មានចំនួន៨៣នាក់ ស្រី៦០នាក់ មកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន៤៦នាក់ (ស្រី៣២នាក់)
- ប្រទេសវៀតណាម ចំនួន០១នាក់ (ស្រី០១នាក់)
- ប្រទេសចិន ចំនួន២០នាក់ (ស្រី២០នាក់)
- ប្រទេសថៃ ចំនួន០៨នាក់ (ស្រី០៥នាក់)
- ប្រទេសឡាវ ចំនួន០៦នាក់
- ប្រទេសសឹង្ហបុរី ចំនួន០១នាក់ (ស្រី០១នាក់)
- អារ៉ាប៊ីសាអូឌីត ចំនួន០១នាក់ (ស្រី០១នាក់)

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះចំនួន១៦នាក់ (ស្រី១៣នាក់) ក្នុងនោះមកពីប្រទេសចិន១១នាក់ ប្រទេសម៉ាឡេស៊ី០៤នាក់ និងអារ៉ាប៊ីសាអូឌីត០១នាក់ តាមការសម្ភាសបានឲ្យដឹងថាទៅតាមរយៈមេខ្យល់ទាំងអស់។

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុបចំនួន៤០នាក់ (ស្រី៣២នាក់ កុមារី០៨នាក់)។ មានដូចខាងក្រោម៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន៣៣នាក់ (ស្រី១៨នាក់ កុមារី០៨នាក់) ក្នុងនោះមកពី៖ ប្រទេសចិន១៨នាក់ ម៉ាឡេស៊ី០៩នាក់ វៀតណាម០៥នាក់(ឆ្លងដែនទៅចិន០៤នាក់ ជួញដូរផ្លូវភេទ០១នាក់) និងអារ៉ាប៊ីសាអូឌីត០១នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយទៅចិន២២នាក់ និងជួញដូរកម្លាំងពលកម្ម១០នាក់ និងជួញដូរផ្លូវ ភេទ០១នាក់) ។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែតបានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសថៃចំនួន០៧នាក់(ស្រី០២នាក់ កុមារ០២នាក់ កុមារី០៣នាក់) ក្នុងនោះទទួលពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សពីប្រទេសថៃ (DSDW)០៣នាក់ និងអង្គការLPN ០៤នាក់ ជាករណីជួញដូរកម្លាំងពលកម្ម។

**ឃ.៣-ការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅទទួលសេវាស្នាក់នៅ(រយៈពេលវែង-ខ្លី) និងស្តារនីតិសម្បទា**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន១០២នាក់(ស្រី៨៩នាក់ កុមារ០៥ កុមារី២៤នាក់)ក្នុងនោះមាន៖

- បានពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន៣៤នាក់ (ស្រី២០នាក់ កុមារី០៨នាក់) ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា៖ អង្គការសម្ព័ន្ធចាប់ដៃ អង្គការរតនៈអន្តរជាតិ អង្គការ មេត្រីអន្តរជាតិ អង្គការ IOM អង្គការសួននៃក្តីសង្ឃឹមកម្ពុជា អង្គការក្តីសង្ឃឹម និងយុត្តិធម៌ អង្គការបេសកកម្ម យុត្តិធម៌អន្តរជាតិ អង្គការសង្គ្រោះជោគវាសនាកម្ពុជា និងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។
- មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ បានធ្វើការពិគ្រោះយោបល់ និងស្តានីតិសម្បទារបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន៣៧នាក់ ទៅទទួលសេវាបន្តនៅមណ្ឌលរបស់រដ្ឋ និងអង្គការដៃគូ ។
- មន្ទីរសង្គមកិច្ចខេត្តតាកែវ បានធ្វើការពិគ្រោះយោបល់ និងស្តានីតិសម្បទារបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៤នាក់ ស្រី៣នាក់ ទៅមណ្ឌលរបស់រដ្ឋ និងអង្គការដៃគូ។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែតបានបញ្ជូលជនរងគ្រោះ ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន១១នាក់ (ស្រី០២នាក់ កុមារ០៥នាក់ កុមារី០៣នាក់) ទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជា៖ អង្គការក្តីសង្ឃឹម និងយុត្តិធម៌ Hope for Justice០៣នាក់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ Justice ០៨នាក់ ។
- អង្គការ និងសមាគមដៃគូ បានទទួលស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន១៦នាក់(ស្រី០៣នាក់ កុមារី១៣នាក់) ដូចជាអង្គការវ៉េណាសេដើរជាមួយស្ត្រីកម្ពុជា០៣នាក់ និងសមាគមកុមារីកាយ១៣ នាក់ (ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម១១នាក់ និងរំលោភសេពសន្ថវៈ០៥នាក់)។

**ឃ.៤-ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) និង

មន្ទីរសង្គមកិច្ចរាជធានី-ខេត្តសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូនានា បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សមានករណី(រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ជួញដូរផ្លូវភេទ និងជួញដូរកម្លាំងពលកម្មសរុបចំនួន២០នាក់ (ស្រី១៩នាក់) ដើម្បីទទួលសេវាស្នាក់នៅសុវត្ថិភាពអប់រំក្នុង និងក្រៅប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាផ្សេងៗ មុននឹងបញ្ជូនទៅសហគមន៍វិញ។

- បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយគ្រោះដោយអំពើជួញដូរមនុស្សចំនួន១៩នាក់ ស្រី១៨នាក់ ក្នុងនោះមានករណី(រៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ១៨នាក់ និងជួញដូរកម្លាំងពលកម្ម០១នាក់)
- មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង បានសហការជាមួយអង្គការតេនៈអន្តរជាតិ ធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០១នាក់ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសចិន ឲ្យវិលត្រឡប់ទៅគ្រួសារ ក្នុងសហគមន៍របស់គាត់វិញ។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការងារបណ្តុះបណ្តាល

លេខាធិការដ្ឋាន នៃគណៈកម្មាធិការ គ.ខ.ប.ជ បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន២៣៣នាក់ ក្នុងនោះមានស្ត្រី ៧២នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការ (AIM SWAT) បើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ។ | ០១ | ២០ | ០៦ |
| ២ | ខេត្តឧត្តរមានជ័យ បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាដល់ជនបង្គោលទាំង៥ក្រុង/ស្រុក។ | ១ | ១៤៣ | ៤៦ |
| ៣ | ខេត្តកំពត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុក និងការស្វែងរកការងារធ្វើប្រកបដោយសុវត្ថិភាព និងស្របច្បាប់។ | ០២ | ៧០ | ២០ |
| សរុប | | **០៤** | **២៣៣** | **៧២** |

#### ១.២-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ៤៧លើក មានអ្នកចូលរួមសរុប៦៧២នាក់ មានស្រី១៣០នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន៣៤លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន០៤លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន០៩លើក ។ (ឧបសម្ព័ន្ធទី២)

### ១. ក្រៅប្រទេស

#### ១.១-វគ្គបណ្តុះបណ្តាល

- អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចាត់នាយ

Ritha

នគរបាលចំនួន០២រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅប្រទេសចិន។

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលចំនួន០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល កម្មវិធីគ្រប់គ្រង និងត្រួតពិនិត្យព្រំដែនលើកទី១៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។
- ខេត្តកំពង់ធំ លេខធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជួញដូរមនុស្ស និងការធ្វើអាជីវកម្មលើកុមារវគ្គទី៧ នៅបណ្ឌិតសភា ILea ទីក្រុងបាងកង ប្រទេសថៃ។

១.២-សិក្ខាសាលា

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានចាត់បញ្ជូននាយនគរបាលចំនួន០១រូប ទៅចូលរួមសិក្ខាសាលា ស្តីពីគម្រោងនៅតំបន់អាស៊ីអាគ្នេយ៍ នៅកោះ PENANG ប្រទេសថៃ។

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជាគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាប្រព័ន្ធ និង

បែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។

- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬ អង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. **ទិសដៅខែសីហា ឆ្នាំ២០១៨**

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្ដាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយ

របស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន** គ.ជ.ប.ជ )។

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រកពរបស់ពលករជាដើម។ Ritha

ថ្ងៃ ច័ន្ទ ៤ កើត ខែ ភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១
## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែកក្កដា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 37 លើក | 2,170 នាក់ | 1,091 នាក់ |
| 2 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ តាមរយៈការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 271 លើក | 15,637 នាក់ | 9,523 នាក់ |
| | | វេទិកាសាធារណៈ ដល់ប្រជាពលរដ្ឋ ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | | 76 លើក | 2,469 នាក់ | 1,308 នាក់ |
| 3 | ខេត្តកណ្ដាល | វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 262 លើក | 17,696 នាក់ | 8,585 នាក់ |
| | | ផ្សព្វផ្សាយ ស្ដីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដោយបញ្ជ្រាបតាមកិច្ចប្រជុំនានា ដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក | 11 លើក | 3,518 នាក់ | 1,389 នាក់ |
| 4 | ខេត្តប៉ៃលិន | ផ្សព្វផ្សាយ ស្ដីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 55 លើក | 2,384 នាក់ | 1,160 នាក់ |
| | | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 44 លើក | 1,964 នាក់ | 879 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្ដីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 569 លើក | 89,830 នាក់ | 45,483 នាក់ |
| | | វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 289 លើក | 11,233 នាក់ | 5,792 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តពោធិ៍សាត់ | ផ្សព្វផ្សាយ ស្តីពីបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 293 លើក | 79,156 នាក់ | 47,571 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្រ្តី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 103 លើក | 11,769 នាក់ | 6,022 នាក់ |
| 7 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្តីពីបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង ស្នងការដ្ឋាននគរបាលខេត្ត | 269 លើក | 39,379 នាក់ | 23,636 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | | 138 លើក | 7,633 នាក់ | 3,754 នាក់ |
| 8 | ខេត្តស្វាយរៀង | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មសង្ស័យថាមានពាក់ព័ន្ធបទល្មើសផ្លូវភេទដូចជា ( ខារ៉ាអូខេ ផ្ទះសំណាក់ ម៉ាស្សាកោសជប់ កាស៊ីណូ ផ្ទះលក់កាហ្វេដេអូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 63 នាក់ | 52 នាក់ |
| 9 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាលក្រុង ស្រុក | 15 លើក | 1,171 នាក់ | 491 នាក់ |
| 10 | ខេត្តកែប | ផ្សព្វផ្សាយ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដោយបញ្ជ្រាបច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយខុសច្បាប់ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 31 លើក | 6,168 នាក់ | 3,248 នាក់ |
| 11 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយ ស្តីពីអំពើជួញដូរមនុស្សដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ នៅតាមគ្រឹះស្ថានសិក្សាក្នុងខេត្ត និងការធ្វើទេសន្តប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ដល់កម្មករ និយោជិក និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 33 លើក | 32,286 នាក់ | 16,351 នាក់ |
| 10 | ខេត្តតាកែវ | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត | 104 លើក | 4,232 នាក់ | 2,138 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 12 | ខេត្តឧត្តរមានជ័យ | ផ្សព្វផ្សាយ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 2,145 នាក់ | 1,560 នាក់ |
| 13 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ និងមន្ត្រីរាជការ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 2 លើក | 205 នាក់ | 104 នាក់ |

សកម្មភាពសរុបចំនួន: 2,619 លើក

មនុស្សសរុបចំនួន: 331,108 នាក់

ស្រីសរុបចំនួន : 180,137 នាក់

## ឧបសម្ព័ន្ធទី២

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៤៧លើក) មនុស្សចំនួន៦៧២នាក់ (ស្រី១៣០នាក់)

| **ស្ថាប័នសម្របសម្រួល** | **សកម្មភាព** |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន៣៤លើក អ្នកចូលរួមសរុបចំនួន៧៦នាក់ (ស្រី១៨នាក់)<br>▪ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**<br>- បានអញ្ជើញជាអធិបតីក្នុង ពិធីសំណេះសំណាលជាមួយភ្នាក់ងារសន្តិសុខការពារក្នុងអំឡុងពេលបោះឆ្នោត របស់ស្នងការដ្ឋានខេត្តកំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ។<br>- បានអញ្ជើញដឹកនាំមន្ត្រីជាន់ខ្ពស់របស់អគ្គលេខាធិការដ្ឋាន រួមនឹងប្រធាននាយកដ្ឋាន មន្ត្រី ក្រសួងសង្គមកិច្ច ចូលរួមសហការជាមួយអាជ្ញាធរដែនដី ដើម្បីចុះពិនិត្យលទ្ធភាពទទួលពលករក្នុងមណ្ឌលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថានភាពពលករវិលត្រលប់តាមច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកទ្វារព្រំដែនអន្តរជាតិដូងខេត្តបាត់ដំបង តាមគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។<br>- បានផ្តល់កិច្ចសម្ភាសន៍ អំពីស្ថានភាពពលករវិលត្រលប់តាមច្រកទ្វារព្រំដែនអន្តរជាតិ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយការការពារសន្តិសុខសម្រាប់រៀបចំការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រនីតិកាលទី៦ ជូនដល់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានផ្តល់កិច្ចសម្ភាសន៍អំពី «ស្ថានភាពពលករវិលត្រលប់តាមច្រកទ្វារព្រំដែនអន្តរជាតិ» នៅស្ថានីយ៍ទូរទស្សន៍បាយ័ន ។<br>- បានអនុញ្ញាតិជំនួបស្វែងយល់ ករណីស្ត្រីពពោះជំនួស ជាមួយតំណាងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សប្រចាំកម្ពុជា OHCHR-Cambodia នៃអង្គការសហប្រជានៅអគ្គលេខាធិការដ្ឋាន ជាតិ គ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាលើផែនការយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ ២០១៩-២០២៣ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ **ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត អគ្គលេខាធិការ គ.ជ.ប.ជ**<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខា ធិការដ្ឋាន គ.ជ.ប.ជ នៅរៀងរាល់ព្រឹកថ្ងៃច័ន្ទ នៃសប្តាហ៍នីមួយៗ<br>១.<u>ក្រុមជំនួយការបង្ការ ទប់ស្កាត់</u> ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុនរ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ៖<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពី កិច្ចពិភាក្សាលើករណីពពោះជំនួស ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ឆៃ ស៊ីណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ នៅសាលប្រជុំអគ្គស្នងការដ្ឋាននគរបាលជាតិ ។<br>- លោកអនុប្រធានក្រុម បានអញ្ជើញចូលរួមស្តាប់បឋកថាចែករំលែកពុទ្ធិ និងបទពិសោធន៍ ក្នុងការរៀបចំសុន្ទរកថា និងសេចក្តីថ្លែងការជាសាធារណៈ ដោយមាន ឯកឧត្តមបណ្ឌិត ច័ន្ទ សំណព្វ អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា វាគ្មិនកិត្តិយស នៅសាលប្រជុំ ទ ក្រសួងមហាផ្ទៃ ។ |

- បានអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តគោលនយោបាយ និងផែនការណ៍សកម្មភាព សម្រាប់អនុវត្តគោលនយោបាយស្តីពី កិច្ចការពារកុមារនៅសាលារៀន ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិត សភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។ អញ្ជើញចូលរួមក្នុងកម្មវិធីនោះ មានវត្តមានសរុបចំនួន ៧៦នាក់ ស្រី១៨នាក់ នាសាលប្រជុំភោជនីយដ្ឋាន ទន្លេបាសាក់២ ។

**២-<u>ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ</u>** លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការរង គជ.ប.ជ.៖

- ដោយផ្អែកតាមរបាយការណ៍និងពត៌មានពីក្រសួងស្ថាប័ន អង្គភាព និង NGO ជាដៃគូក្នុងខែកក្កដា ឆ្នាំ ២០១៨នេះ ក្រុមជំនួយកិច្ចការការពារជនរងគ្រោះទទួលបានចំនួនជនសង្ស័យ ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលអាជ្ញាធរបរទេសបញ្ជូនត្រលប់មកកម្ពុជាវិញមានចំនួន៥២នាក់។ ក្នុងនោះរួមមានប្រទេសចំនួន០៥ ដូចខាងក្រោម៖
  - ប្រទេសម៉ាឡេស៊ី ចំនួន៣១នាក់ (ស្ត្រី២៥នាក់ កុមារ០២នាក់) ទៅធ្វើការខុសច្បាប់។
  - ប្រទេសអេហ្ស៊ីប ស្ត្រីចំនួន០១នាក់ មិនអាចទ្រាំទ្រនិងការងារលំបាកបាន
  - ប្រទេសចិន ស្ត្រីចំនួន១៣នាក់ ទៅរៀបការនៅប្រទេសចិន។
  - ប្រទេសថៃ ចំនួន០៣នាក់(អនីតិជនអយុចាប់ពី១៣ដល់១៦ឆ្នាំ) រងគ្រោះដោយអំពើជួញដូរមនុស្ស

**៣-<u>ក្រុមជំនួយកិច្ចការអនុវត្តច្បាប់</u>** ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គលេខាធិការរង គជ.ប.ជ.៖

- ទំនាក់ទំនង និងជំរុញក្រុមការងារយុត្តិធម៌ ដើម្បីស្រង់យកចំនួនតួលេខដម្រះក្តីពីក្រសួងយុត្តិធម៌។

**៤-<u>ក្រុមជំនួយកិច្ចការយុត្តិធម៌</u>** ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង គជ.ប.ជ.៖

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង នៅអគ្គស្នងដ្ឋាននគរបាលជាតិ ដឹកនាំដោយ**លោកជំទាវ យក់ សុខា** អគ្គស្នងការរងនគរបាលជាតិ និងជាតំណាងក្រុមអនុវត្តច្បាប់ ពិភាក្សាលើការអនុវត្តបន្តក្រោយពីការបង្ក្រាបករណីពពោះជំនួស។

**៥-<u>ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ</u>** លោកជំទាវ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង គជ.ប.ជ.៖

- បានចូលរួមកិច្ចប្រជុំ Comment on EU Commission Concern ។
- បានចូលរួមកិច្ចប្រជុំជាមួយ ឯកឧត្តម ងី ច័ន្ទផល និងក្រុមការងារ EU ប្រចាំក្រសួងមហាផ្ទៃលើការឆ្លើយតប EU។
- បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារ បេសកកម្មសហគមន៍អឺរ៉ុប ដែលប្រព្រឹត្តទៅសាលប្រជុំ B នៃទីស្តីការក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានការចូល រួមពីក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន។
- បានចូលរួមប្រជុំជាមួយ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ទាក់ទងនឹងការធ្វើរបាយការណ៍សម្រាប់ឆ្នាំ ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

- លោកវរសេនីយ៍ឯក អ៊ិន មាន បានចូលរួមសហការជាមួយក្រុមការងារវិបសាយបញ្ចូលទិន្នន័យអង្គការ និងកម្មវិធីសម្រាប់ប្រើលើទូរស័ព្ទ )Mobile App) ដើម្បីធ្វើការរៀបចំ Resource Database។
- ក្រុមការងារបានរៀបចំកែតម្រូវទៅលើឯកសារពង្រាងទម្រង់នៃការចុះឈ្មោះ អង្គការដើម្បីត្រៀមដាក់ក្នុងកិច្ចប្រជុំសម្រេចលើកក្រោយ។

៦-<u>ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍</u> ឯកឧត្តម ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា អគ្គលេខាធិការរង គជ.ប.ជ.៖

- ចូលរួមប្រជុំជាមួយក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់និងតំណាងក្រសួងពាក់ព័ន្ធមួយចំនួនទៀតស្តីពីការផ្តល់ធាតុចូលក្នុងផែនការយុទ្ធសាស្ត្រជាតិរយៈពេល៥ឆ្នាំ របស់ក្រុមយុទ្ធសាស្ត្រទី២ ក្រោមប្រធានបទ “ ការលើកកម្ពស់ការបង្ការទប់ស្កាត់នូវរាល់ទំរង់នៃអំពើជួញដូរមនុស្ស ” ។
- បានធ្វើរបាយការណ៍ស្តីពីបេសកកម្មអមដំណើរ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ ដើម្បីអង្កេត និងស្វែងយល់ពីស្ថានភាពចាប់បញ្ជូនពលករកម្ពុជាដាក់ស្តែងតាមច្រកទ្វារព្រំដែនអន្តរជាតិទាំងពីរខាងលើ ដាក់ជូនលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងឯកឧត្តម អគ្គលេខាធិការ គ.ជ.ប.ជ ពិនិត្យ និងជ្រាបជារបាយការណ៍។
- បានទំនាក់ទំនងទៅលោកវរសេនីយ៍ត្រី សៀង ចន្នី មន្ត្រីនគរបាលអន្តោប្រវេសន៍ ទទួលបន្ទុករដ្ឋបាល ប្រចាំប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង ស្នើសុំតួលេខពលករទេសន្តប្រវេសន៍ខុសច្បាប់ ដែលត្រូវអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ពីថ្ងៃទី០១ដល់១៣ កក្កដា ដើម្បីធ្វើការប្រៀបធៀបរវាងចំនួនចាប់បញ្ជូនមកមុន និងក្រោយថ្ងៃប្រកាសបញ្ចប់ការផ្តល់ភាពស្របច្បាប់របស់អាជ្ញាធរថៃនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។
- បានទំនាក់ទំនងទៅលោកវរសេនីយ៍ត្រី សៀង ចន្នី ដដែល ដើម្បីសុំផ្ញើរចំនួនតួលេខពលករខុសច្បាប់ដែលអាជ្ញាធរថៃចាប់បញ្ជូនក្នុងត្រីមាសទី២ខែមេសា ខែមិថុនា និងចំនួនសាកសពពលករកម្ពុជាដែលបញ្ជូនមកតាមច្រកទ្វារព្រំដែនអន្តរជាតិដូង សំរាប់ឆមាសទី១ពីខែមករា-មិថុនាជា លទ្ធផលបានទទួលរួចហើយ។
- បានទំនាក់ទំនងទៅលោក អ៊ុក រ៉ាវុធ ស្នើសុំរបាយការណ៍ឆមាសទី១ ឆ្នាំ២១០៨ ស្តីពីការអនុវត្តន៍សកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ក្រសួង ក.វ.ប ជាលទ្ធផលបានទទួលរួចហើយ។
- បានទំនាក់ទំនងទៅលោក ហ៊ិន ឧសភា មន្ត្រីនាយកដ្ឋានច្បាប់ និងកិច្ចការកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំតារាងលទ្ធផលដែលបានអន្តរាគមន៍ ជួយសង្គ្រោះនិងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរដែលរងគ្រោះនៅបរទេសក្នុងខែមិថុនា ឆ្នាំ២១០៨ ជាលទ្ធផលបានទទួលរួចហើយ ។
- បានធ្វើរបាយការណ៍ជូនឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុកក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ស្តីពីការស្រាវជ្រាវ និងតាមដានចំនួនពលករទេសន្តរប្រវេសន៍ដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង និងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យទាំង០៤សប្តាហ៍ក្នុងខែកក្កដានេះ តាមរយៈលោកវរសេនីយ៍ចន្នីនាយរងការិយាល័យប្រឆាំងការជួញដូរ ត្រីសៀង និងលោកវរសេនីយ៍ត្រី (នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង) មនុស្ស និងការពារអនីតិជន ដែលឈរជើងនៅទីស្នាក់ការទទួលពាក្យបណ្តឹងជនរងគ្រោះក្នុងក្រុងប៉ោយប៉ែត សម្រាប់ទុកធ្វើការប្រៀបធៀបប្រចាំសប្តាហ៍។
- បានទំនាក់ទំនងស្នើសុំចំនួនពលករកម្ពុជា ដែលត្រូវអាជ្ញាធរថៃចាប់បញ្ជូនមកវិញរយៈពេល ៣ខែក្រោយ (មេសា ឧសភា មិថុនា ឆ្នាំ២០១៨)និងចំនួនសាកសពពលករខ្មែរដែលបញ្ជូនមកកតាមច្រកទ្វារព្រំដែនអន្តជាតិប៉ោយប៉ែត រយៈពេល ០៦ខែ (ពីខែមករា ដល់ មិថុនា ឆ្នាំ២០១៨)ពីលោក វួច អូន ប្រធានស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ប៉ោយប៉ែត ជាលទ្ធផល ពុំទាន់មានការឆ្លើយតបឡើយ ។

| | |
|---|---|
| | **៧-ការងាររដ្ឋបាលរបស់លេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់គ.ជ.ប.ជ៖ (លិខិតចេញ ១៣ច្បាប់)(លិខិតចូល១០ច្បាប),លិខិតរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖ ( លិខិតចេញ៦ច្បាប់លិខិតចូល១២ច្បាប់)។<br>- ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី និងរៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមិថុនា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បូកសរុបរបាយការណ៍ខែមិថុនា ត្រីមាសទី២ និងឆមាសទី១ឆ្នាំ២០១៨ របស់ គ ជ.ប.ជនិងប្រមូលរបាយការណ៍តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវ័តី និងគ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ |
| អគ្គនាយកដ្ឋានអន្តោប្រវេសន៍ | ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត **សុខ ផល** អគ្គនាយកអន្តោប្រវេសន៍ បានអញ្ជើញចូលរួម៖<br>• ពិធីចុះហត្ថលេខាប្រគល់ទទួលសម្ភារៈជំនួយរបស់ក្រសួងនគរបាល នៃសាធារណៈរដ្ឋនិយមវៀតណាម ជូនក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា។<br>• កិច្ចប្រជុំពិភាក្សាការអនុវត្តច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដឹកនាំប្រជុំដោយ ឯកឧត្តម ប៊ុន ហុន អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ។<br>• ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោយអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធគ្រឿងញៀន។<br>• ជួបពិភាក្សាការងារជាមួយលោកស្រី សេ ស៊ីលា តំណាងនគរបាលនៃប្រទេស NORDIC ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ និសហការី។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន០៩លើក អ្នកចូលរួមសរុបចំនួន៥៩៦នាក់ (ស្រី១១២នាក់)** | |
| ខេត្តកណ្តាល | - បានរៀបចំកិច្ចប្រជុំចំនួន០៧លើក អ្នកចូលរួមចំនួន៥៦៣នាក់ ស្រី១០៧នាក់៖<br>• គណៈកម្មាធិការ គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដាចំនួន០១លើក នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលមានអ្នកចូលរួមចំណុះឲ្យមន្ទីរសរុបចំនួន៣៦៩នាក់ ។<br>• ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែកក្កដាចំនួន០៥លើក មានអ្នកចូលរួមចំនួន១៣៤នាក់ ស្រី៨២នាក់<br>• លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន៦០នាក់ ស្រី២៥នាក់។ |
| ខេត្តប៉ៃលិន | - ឯកឧត្តម ផាន់ ចាន់ ធុល ប្រធានគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានដឹកនាំកិច្ចប្រជុំ ពិនិត្យពិភាក្សាសេចក្តីព្រាង ស្តីពីការកែសម្រួលសមាសភាព និងរបាយការណ៍ឆមាសទី១ ឆ្នាំ២០១៨ ដែលមានអ្នកចូលរួមចំនួន៣២នាក់ ស្រី០៥នាក់ ។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបពិភាក្សាការងារជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) ស្តីពីបទល្មើសឆ្លងដែនពាក់ព័ន្ធនឹងការរំលោភបំពានលើកុមារ។ |